ច្បាប់ស្តីពីសិទ្ធិរបស់អ្នកបោះឆ្នោតនៅរដ្ឋម៉ាសាឈូសេត

ច្បាប់ការពារសិទ្ធិបោះឆ្នោតរបស់អ្នក។

ច្បាប់រក្សាសិទ្ធិនេះជូនអ្នកដែលបានចុះឈ្មោះបោះឆ្នោតត្រឹមត្រូវរួចហើយ។

១) អ្នកមានសិទ្ធិបោះឆ្នោត ប្រសិនបើអ្នកបានចុះឈ្មោះបោះឆ្នោតត្រឹមត្រូវរួចហើយ។

២) អ្នកមានសិទ្ធិបោះឆ្នោតដោយសម្ងាត់។ អ្នកមានសិទ្ធិបោះឆ្នោត ដោយមិនស្ថិតក្រោមឥទ្ធិពលជនណាម្នាក់ និង បោះឆ្នោតក្នុងបន្ទប់សម្ងាត់ គ្មាននរណាអាចលបមើលឃើញអ្នកគូសលើសន្លឹកឆ្នោត។

៣) អ្នកមានសិទ្ធិមានវត្តមានក្នុងបន្ទប់បោះឆ្នោតចំនួន ៥ នាទី ប្រសិនបើអ្នកបោះឆ្នោតផ្សេងទៀតកំពុងរង់ចាំ និង មានសិទ្ធិមានវត្តមានក្នុងបន្ទប់បោះឆ្នោតចំនួន ១០ នាទី ប្រសិនបើគ្មានអ្នកបោះឆ្នោតដទៃទៀតកំពុងរង់ចាំ។

៤) អ្នកមានសិទ្ធិសុំប្តូរសន្លឹកឆ្នោតថ្មី ២ ដង ប្រសិនបើធ្វើខុស និង ធ្វើឱ្យសន្លឹកឆ្នោតខូចលែងប្រើការបាន។

៥) អ្នកមានសិទ្ធិស្នើសុំឱ្យនរណាម្នាក់ជួយអ្នកទៅតាមការពេញចិត្ត នៅពេលបោះឆ្នោត។ ប្រសិនបើអ្នកមិនបាននាំនរណាម្នាក់ទៅតាមដើម្បីជួយ អ្នកមានសិទ្ធិស្នើសុំបុគ្គលិកការិយាល័យបោះឆ្នោត ២ នាក់ ដើម្បីជួយអ្នក។

៦) ជនពិការក៏មានសិទ្ធិបោះឆ្នោត។ ស្ថានីយ៍បោះឆ្នោត និង បន្ទប់បោះឆ្នោតត្រូវតែមានលក្ខណៈងាយស្រួល ដើម្បីឱ្យជនពិការអាចបោះឆ្នោតបាន។

៧) អ្នកមានសិទ្ធិបោះឆ្នោត ប្រសិនបើអ្នកមិនចេះអាន ឬ មិនចេះសរសេរភាសាកំណើត ឬ មិនចេះអាន ឬ សរសេរភាសាអង់គ្លេស។

៨) អ្នកមានសិទ្ធិបោះឆ្នោត ប៉ុន្តែ អ្នកត្រូវបង្ហាញអត្តសញ្ញាណសម្គាល់ខ្លួន ប្រសិនបើ៖ អ្នកជាអ្នកបោះឆ្នោតលើកដំបូងដែលបានចុះឈ្មោះតាមប្រៃសនីយ៍ និង មិនបានផ្ញើអត្តសញ្ញាណសម្គាល់ខ្លួនពេលផ្ញើពាក្យសុំចុះឈ្មោះបោះឆ្នោត ឬ ឈ្មោះអ្នកមានក្នុងបញ្ជីអ្នកបោះឆ្នោតអកម្ម ឬ សម្លេងឆ្នោតអ្នកមានការជំទាស់ ឬ បុគ្គលិកស្ថានីយ៍បោះឆ្នោតស្នើសុំឱ្យបង្ហាញអត្តសញ្ញាណ។ អត្តសញ្ញាណសម្គាល់ខ្លួនដែលអាចទទួលយកបាន មានដូចជា៖ ប័ណ្ណបើកបរ ឯកសារមានឈ្មោះ និង អាសយដ្ឋានអ្នក ដូចជាវិក័យប័ត្រទឹកភ្លើងថ្មីៗ បង្កាន់ដៃជួលផ្ទះមានក្បាលលិខិតពីម្ចាស់ផ្ទះ កិច្ចសន្យាជួល ឬ លិខិតទទួលស្គាល់ ឬ បង្កាន់ដៃទទួលស្គាល់អ្នកចុះឈ្មោះបោះឆ្នោត។

៩) អ្នកមានសិទ្ធិបោះឆ្នោតមុនថ្ងៃបោះឆ្នោត ដោយប្រើសន្លឹកឆ្នោតសម្រាប់អ្នកអវត្តមាន ប្រសិនបើ៖ អ្នកនឹងមិនបាននៅក្រុងអ្នកនៅថ្ងៃបោះឆ្នោត ឬ ប្រសិនបើអ្នកមានពិការផ្នែករាងកាយ ដែលមិនអាចឱ្យអ្នកចេញទៅបោះឆ្នោតបាន ឬ ប្រសិនបើអ្នកមិនអាចទៅបោះឆ្នោតនៅស្ថានីយ៍បោះឆ្នោត ដោយសារជំនឿសាសនារបស់អ្នក។

១០) អ្នកមានសិទ្ធិបោះឆ្នោត ដោយប្រើសន្លឹកឆ្នោតបណ្តោះអាសន្ន ប្រសិនបើអ្នកជឿថាអ្នកបានចុះឈ្មោះបោះឆ្នោតត្រឹមត្រូវរួចហើយ ប៉ុន្តែ បុគ្គលិកស្ថានីយ៍បោះឆ្នោតប្រាប់អ្នកថា អ្នកគ្មានសិទ្ធិបោះឆ្នោត។

១១) អ្នកមានសិទ្ធិប្តឹង និង តាមដានបណ្តឹងនេះ ដើម្បីឱ្យគេស៊ើបអង្កេតបញ្ហាបំពានលើសិទ្ធិបោះឆ្នោតរបស់អ្នក។

១២) អ្នកមានសិទ្ធិបោះឆ្នោត ប្រសិនបើពេលបច្ចុប្បន្ន អ្នកមិនជាប់ពន្ធនាគារពីបទឧក្រិដ្ឋណាមួយ និង ប្រសិនបើអ្នកបានចុះឈ្មោះបោះឆ្នោតនៅបន្ទាប់ពីតុលាការដោះលែងអ្នកឱ្យមានសេរីភាព។

១៣) អ្នកមានសិទ្ធិយកទៅតាមខ្លួនទៅក្នុងបន្ទប់បោះឆ្នោត នូវច្បាប់ស្តីពីសិទ្ធិរបស់អ្នកបោះឆ្នោតនេះ ឬ ឯកសារដទៃទៀត រួមទាំងគំរូសន្លឹកឆ្នោតសេចក្តីណែនាំអ្នកបោះឆ្នោត ឬ សម្ភារៈធ្វើយុទ្ធនាការបោះឆ្នោត។ សូមកុំភ្លេចយកឯកសារទាំងអស់នោះចេញពីបន្ទប់បោះឆ្នោត នៅពេលអ្នកចេញមកវិញ។

១៤) អ្នកមានសិទ្ធិបោះឆ្នោតនៅស្ថានីយ៍បោះឆ្នោតអ្នក ពេលណាក៏បាន ចាប់ពីម៉ោង ៧ ព្រឹក ដល់ ម៉ោង ៨ យប់ សម្រាប់ការបោះឆ្នោតថ្នាក់រដ្ឋ និង ថ្នាក់ជាតិ។ ម៉ោងបោះឆ្នោតអាចខុសគ្នា សម្រាប់ការបោះឆ្នោតមូលដ្ឋាន។ នៅម៉ោង ៨ យប់ ប្រសិនបើអ្នកកំពុងឈរតម្រង់ជួរនៅស្ថានីយ៍បោះឆ្នោតណាមួយ ទោះស្ថានីយ៍នោះបិទទ្វារម៉ោង ៨ យប់ក៏ដោយ ក៏អ្នកនៅតែមានសិទ្ធិបោះឆ្នោតបានដែរ។

១៥) អ្នកមានសិទ្ធិនាំកូនចូលទៅក្នុងបន្ទប់បោះឆ្នោតជាមួយអ្នកបាន។

ប្រសិនបើអ្នកគិតថា សិទ្ធិបោះឆ្នោតរបស់អ្នកត្រូវបានរំលោភបំពានដោយប្រការណាមួយ សូមទូរស័ព្ទទៅកាន់លេខាធិការនៃនាយដ្ឋានបោះឆ្នោតរដ្ឋម៉ាសាឈូសេត តាមរយៈលេខ 1-800-462-VOTE (8683)។ ទូរស័ព្ទទៅលេខនេះ ដោយឥតគិតថ្លៃ ក្នុងរដ្ឋម៉ាសាឈូសេត។

ព័ត៌មានស្តីពីច្បាប់ជាតិ និង ច្បាប់រដ្ឋ ដែលហាមឃាត់ការបោកបន្លំ និង ការថ្លែងបោកប្រាស់៖

ខាងក្រោមនេះជាច្បាប់គោលស្តីអំពីការរំលោភបំពាន

អនុលោមតាមច្បាប់ជាតិ និង/ឬ ច្បាប់រដ្ឋ៖

- ជនគ្រប់រូបមិនត្រូវក្លែងព័ត៌មាន ឬ អះអាងថាខ្លួនជាពលរដ្ឋរបស់សហរដ្ឋអាមេរិក ដើម្បីចុះឈ្មោះបោះឆ្នោត ឬ ទៅបោះឆ្នោតក្នុងការបោះឆ្នោតជាតិ រដ្ឋ ឬ ថ្នាក់មូលដ្ឋាន។
- ជនគ្រប់រូប រួមទាំងបេក្ខជនថ្នាក់ជាតិមិនត្រូវផ្តល់ ឬ ផ្ញើពាក្យសុំចុះឈ្មោះបោះឆ្នោត ដែលក្លែងបន្លំ មិនសុចរិត ឬ ប្រឌិតក្នុងការបោះឆ្នោតណាមួយ។
- ជនគ្រប់រូប រួមទាំងបេក្ខជនថ្នាក់ជាតិមិនត្រូវក្លែងព័ត៌មានអំពីឈ្មោះ អាសយដ្ឋាន ឬ រយៈពេលស្នាក់នៅ នៅក្នុងស្រុកនៃមណ្ឌលបោះឆ្នោត ក្នុងគោលបំណងបញ្ជាក់ភាពមានសិទ្ធិចុះឈ្មោះ ឬ បោះឆ្នោត នៅក្នុងការបោះឆ្នោតណាមួយ។
- ជនគ្រប់រូប រួមទាំងបេក្ខជនថ្នាក់ជាតិមិនត្រូវផ្តល់ ឬ បោះឆ្នោតដោយប្រើសន្លឹកឆ្នោតក្លែងក្លាយ មិនសុចរិត ឬ ប្រឌិតក្នុងការបោះឆ្នោតណាមួយ។
- ជនគ្រប់រូប រួមទាំងបេក្ខជនថ្នាក់ជាតិមិនត្រូវបង់ប្រាក់ ផ្តល់ប្រាក់ ឬ ទទួលយកប្រាក់ជាថ្នូរនឹងការបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត ការបង្ហាំងសម្លេងឆ្នោតរបស់អ្នកបោះឆ្នោត ឬ ជាថ្នូរនឹងការបោះឆ្នោតគាំទ្រ ឬ ប្រឆាំងបេក្ខជនណាម្នាក់នៅក្នុងការបោះឆ្នោតណាមួយ។
- ជនគ្រប់រូបមិនត្រូវបង្អាក់ ឬ ធ្វើឱ្យខូច ឬ ប៉ុនប៉ងបង្អាក់ ឬ ប៉ុនប៉ងធ្វើឱ្យខូចម៉ាស៊ីនណាមួយដែលត្រូវបានប្រើ ឬ កំពុងត្រូវបានប្រើសម្រាប់ការបោះឆ្នោត ក្នុងពេលបោះឆ្នោត ឬ រារាំងមិនឱ្យម៉ាស៊ីននោះធ្វើដំណើរការបានត្រឹមត្រូវ។
- ជនគ្រប់រូបមិនត្រូវរារាំង ពន្យារពេល ឬ ជ្រៀតជ្រែក និង ចូលដៃក្នុងការរារាំង ពន្យារពេល ឬ ជ្រៀតជ្រែកអ្នកបោះឆ្នោតណាម្នាក់ នៅពេលគាត់កំពុងធ្វើដំណើរតាមផ្លូវទៅបោះឆ្នោតសាកល្បង ការប្រជុំគណៈបក្សនយោបាយ ឬ ការបោះឆ្នោត នៅពេលកំពុងតម្រង់ជួរ ឬ នៅពេលកំពុងគូសសន្លឹកឆ្នោត ឬ នៅពេលកំពុងបោះឆ្នោត ឬ កំពុងប៉ុនប៉ងបោះឆ្នោត ឬ ព្យាយាមលួងលោមអ្នកបោះឆ្នោតណាម្នាក់ នៅមុនពេលទម្លាក់សន្លឹកឆ្នោតទៅក្នុងហិបឆ្នោត ដើម្បីបង្ហាញឱ្យឃើញថាគាត់បានគូសយ៉ាងម៉េចនៅលើសន្លឹកឆ្នោតរបស់ពួកគាត់។
- ជនគ្រប់រូបមិនត្រូវយកសន្លឹកឆ្នោតចេញពីបរិវេណនៃរបាំងដែលដាក់ឃាំងកន្លែងបោះឆ្នោត នៅមុនពេលបិទស្ថានីយ៍បោះឆ្នោត។
- ជនគ្រប់រូបមិនត្រូវបោះឆ្នោត ឬ ប៉ុនប៉ងបោះឆ្នោតនៅកន្លែងបោះឆ្នោតណាមួយ នៅពេលដឹងខ្លួនឯងថាគ្មានសិទ្ធិបោះឆ្នោតនៅកន្លែងនោះ។
- ជនគ្រប់រូបមិនត្រូវបោះឆ្នោត ឬ ប៉ុនប៉ងបោះឆ្នោតលើសពីមួយដងនៅកន្លែងបោះឆ្នោតដដែល។
- ជនគ្រប់រូបមិនត្រូវបោះឆ្នោត ឬ ប៉ុនប៉ងបោះឆ្នោតដោយប្រើឈ្មោះអ្នកដទៃក្រៅពីឈ្មោះខ្លួនឯង។
- ជនគ្រប់រូបមិនត្រូវជួយ ឬ ផ្តល់ជំនួយដល់ជនណាម្នាក់ដែលគ្មានសិទ្ធិបោះឆ្នោត ឱ្យអាចបោះឆ្នោតបាន ឬ ប៉ុនប៉ងបោះឆ្នោត ឬ ជួយក្នុងការបោះឆ្នោត ឬ ប៉ុនប៉ងបោះឆ្នោតដោយប្រើឈ្មោះអ្នកដទៃក្រៅពីឈ្មោះខ្លួនឯង ឬ ជួយក្នុងការបោះឆ្នោត ឬ ប៉ុនប៉ងបោះឆ្នោតលើសពីមួយសន្លឹក។
- ជនគ្រប់រូបមិនត្រូវគូសសញ្ញាសម្គាល់ណាមួយនៅលើសន្លឹកឆ្នោតរបស់ខ្លួន ឬ កុហកថាខ្លួនមិនចេះគូសសន្លឹកឆ្នោត ឬ បង្ហាញសន្លឹកឆ្នោតដែលខ្លួនបានគូសឱ្យអ្នកដទៃឃើញ ក្នុងគោលបំណងដែលច្បាប់មិនអនុញ្ញាត ឬ ឆ្លើយកុហក ឬ ធ្វើសម្បថមិនពិតទៅមន្ត្រីបោះឆ្នោត។
- ជនគ្រប់រូបមិនត្រូវប្រព្រឹត្តឥតសណ្តាប់ធ្នាប់។
- ជនគ្រប់រូបត្រូវគោរពតាមការបញ្ជាស្របច្បាប់នៃមន្ត្រីបោះឆ្នោត។
- ជនគ្រប់រូបមិនត្រូវរារាំងការបោះឆ្នោត។
- ជនគ្រប់រូបមិនត្រូវតតាំងជាមួយអ្នកមានសិទ្ធិបោះឆ្នោត ក្នុងគោលបំណងរើសអើង ឬ ដើម្បីចង់ដឹងរបៀបបោះឆ្នោតរបស់គាត់ ឬ ដើម្បីគោលបំណងខុសច្បាប់ដទៃទៀត។

ជនណាបំពានប្រការណាមួយដូចខាងលើ ជននោះនឹងទទួលការផាកពិន័យ និង/ឬ ជាប់ពន្ធនាគារ។

សេចក្តីណែនាំសម្រាប់អ្នកបោះឆ្នោត

មុនបោះឆ្នោត

សូមប្រាប់អាសយដ្ឋាន និង ឈ្មោះអ្នកទៅមន្ត្រីបោះឆ្នោត។

ប្រសិនបើអ្នកត្រូវការឱ្យគេជួយ ដោយសារតែអ្នកពិការភ្នែក ពិការដៃជើង មិនចេះអានភាសាកំណើត ឬ ភាសាអង់គ្លេស អ្នកអាចសុំឱ្យនរណាម្នាក់ជួយអ្នកទៅតាមការជ្រើសរើសរបស់អ្នក ឬ អ្នកអាចសុំឱ្យមន្ត្រីបោះឆ្នោតពីរនាក់ មកពីគណៈបក្សនយោបាយផ្សេងគ្នា ឱ្យជួយអ្នកបាន។ អ្នកអាចសុំឱ្យមន្ត្រីបោះឆ្នោតប្រើម៉ាស៊ីនជំនួយសម្រាប់គូសសន្លឹកឆ្នោត ជាឧបករណ៍សម្រាប់ជួយគូសសន្លឹកឆ្នោត ដើម្បីគូសសន្លឹកឆ្នោតឱ្យអ្នក។

សូមចូលទៅក្នុងបន្ទប់បោះឆ្នោត រួចហើយគូសសន្លឹកឆ្នោតអ្នក។

អ្នកមានពេល ១០ នាទី ដើម្បីបោះឆ្នោត ប៉ុន្តែ ប្រសិនបើមានអ្នកបោះឆ្នោតដទៃទៀតកំពុងរង់ចាំ អ្នកមានពេលតែ ៥ នាទី។

អត្តសញ្ញាណសម្គាល់ខ្លួន

ដោយសារច្បាប់ជាតិ ច្បាប់ឆ្នាំ ២០០២ ស្តីពីជំនួយអ្នកបោះឆ្នោត ត្រូវបានអនុម័តដោយសភា ប្រសិនបើអ្នកចុះឈ្មោះបោះឆ្នោតតាមសំបុត្រប្រៃសនីយ៍នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៣ ឬ នៅក្រោយកាលបរិច្ឆេទនេះ អ្នកត្រូវបង្ហាញអត្តសញ្ញាណសម្គាល់ខ្លួន ពេលអ្នកចេញទៅបោះឆ្នោតលើកដំបូងក្នុងការបោះឆ្នោតជាតិ។ អត្តសញ្ញាណសម្គាល់ខ្លួនដែលអាចទទួលយកបានត្រូវមានឈ្មោះ និង អាសយដ្ឋានអ្នក ដែលអ្នកបានចុះឈ្មោះបោះឆ្នោត ឧទាហរណ៍រូបថតសម្គាល់ខ្លួនដែលថតថ្មីៗ ឬ វិក័យប័ត្រទឹកប្រភ្លើង របាយការណ៍ធនាគារ សែកបើកប្រាក់ខែ សែករដ្ឋាភិបាល ឬ ឯកសារផ្សេងទៀតរបស់រដ្ឋ ដែលមានឈ្មោះ និង អាសយដ្ឋានអ្នក។

ប្រសិនបើអ្នកមិនផ្តល់អត្តសញ្ញាណសម្គាល់ខ្លួនណាមួយដូចខាងលើ ច្បាប់ឆ្នាំ ២០០២ ស្តីពីជំនួយអ្នកបោះឆ្នោតអាចអនុញ្ញាតឱ្យអ្នកបោះឆ្នោតបាន ដោយប្រើសន្លឹកឆ្នោតបណ្តោះអាសន្ន។ សន្លឹកឆ្នោតបណ្តោះអាសន្នត្រូវរាប់នៅពេលក្រោយ គឺគេរាប់វា ក្រោយពីគេអាចកំណត់លើភាពស្របច្បាប់ក្នុងការបោះឆ្នោតអ្នករួចសិន។

ប្រសិនបើគេមិនអនុញ្ញាតឱ្យអ្នកបោះឆ្នោត

ប្រសិនបើអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែ ឈ្មោះអ្នកត្រូវបានគេលុបពីបញ្ជីអ្នកបោះឆ្នោត ឬ ចុះខុសបញ្ជី អ្នកអាចស្នើសុំបោះឆ្នោតបាន តាមរយៈការបង្ហាញខ្លួននៅចំពោះមុខមន្ត្រីបោះឆ្នោតក្រុង នៅសាលាក្រុង ឬ អ្នកអាចបោះឆ្នោតបានដោយប្រើសន្លឹកឆ្នោតបណ្តោះអាសន្ន។

ដើម្បីបោះឆ្នោតបណ្តោះអាសន្ន អ្នកត្រូវការបញ្ជាក់សន្លឹកឆ្នោតបណ្តោះអាសន្ននេះនៅចំពោះមុខមន្ត្រីប្រចាំមណ្ឌល នៅការិយាល័យបោះឆ្នោត ដើម្បីប្រកាសថា អ្នកត្រូវបានចុះឈ្មោះរួចនៅក្នុងក្រុងនៃមណ្ឌលបោះឆ្នោតនោះ និង អ្នករស់នៅក្នុងរង្វង់ខ័ណ្ឌសីមានៃមណ្ឌលបោះឆ្នោតនោះ។ អ្នកបោះឆ្នោតបណ្តោះអាសន្នទាំងអស់ ត្រូវបង្ហាញអត្តសញ្ញាណសម្គាល់ខ្លួនសមស្របមួយ។

បោះឆ្នោតឱ្យបេក្ខជន និង សំណើ

សូមបោះឆ្នោតឱ្យបេក្ខជន ឬ សំណើណាមួយ ដោយគូសបំពេញក្នុងរង្វង់ពងក្រពើ ▭ ដែលនៅជាប់នឹងបេក្ខជន ឬ សំណើដែលអ្នកចង់បោះឆ្នោតឱ្យ។ ត្រូវគូសបំពេញក្នុងរង្វង់ដូច្នេះ ▬ ។ សូមពិនិត្យមើលឈ្មោះបេក្ខជន និង សំណើនៅលើសន្លឹកឆ្នោត មុននឹងសម្រេចបោះឆ្នោត។ **សូមពិនិត្យមើលរាល់សំណើដែលមាននៅលើសន្លឹកឆ្នោត ដ្បិតសំណើខ្លះទៀតអាចមាននៅខាងខ្នង។ សូមកុំបោះឆ្នោតឱ្យបេក្ខជនលើសពីចំនួនអនុញ្ញាតសម្រាប់ការបោះឆ្នោតនីមួយៗ។**

សរសេរឈ្មោះបេក្ខជន

ប្រសិនបើអ្នកចង់បោះឆ្នោតឱ្យបេក្ខជនណាម្នាក់ ដែលគ្មានឈ្មោះលើសន្លឹកឆ្នោត សូមសរសេរឈ្មោះ និង អាសយដ្ឋានបេក្ខជននោះ ឬ យកស្ទីកឃើទៅបិទនៅកន្លែងដែលចន្លោះទំនេរសម្រាប់បិទឈ្មោះបេក្ខជន រួចហើយគូសបំពេញក្នុងរង្វង់រាងពងក្រពើនៅខាងស្តាំដៃ។

សន្លឹកឆ្នោតមិនបានការ

ប្រសិនបើអ្នកចង់ប្តូរសន្លឹកឆ្នោតដែលអ្នកបានបោះរួច សូមប្រគល់សន្លឹកឆ្នោតនោះទៅអ្នកកាន់បញ្ជីសន្លឹកឆ្នោត ដើម្បីប្តូរយកសន្លឹកឆ្នោតថ្មី។ អ្នកអាចស្នើសុំប្តូរសន្លឹកឆ្នោតថ្មីបានពីរសន្លឹក។

ក្រោយពីបោះឆ្នោតរួច

មុននឹងចាកចេញពីបន្ទប់បោះឆ្នោត សូមពិនិត្យមើលថាតើអ្នកបានបោះឆ្នោតជូនបេក្ខជន និង សំណើនៅលើសន្លឹកឆ្នោតគ្រប់ហើយឬនៅ។ សូមដាក់សន្លឹកឆ្នោតអ្នកទៅក្នុងស្រោមក្រដាសសម្ងាត់សិន មុននឹងដាក់វាចូលហិបឆ្នោត។

ហាមបត់ ឬ កាច់ ឬ ធ្វើឱ្យខូចសន្លឹកឆ្នោត។ ត្រូវរក្សាទម្រង់សន្លឹកឆ្នោត ដើម្បីវាអាចឆ្លងកាត់ឧបករណ៍ស្កេនបាន។
ហាមបង្ហាញឱ្យអ្នកដទៃឃើញរបៀបគូសលើសន្លឹកឆ្នោតអ្នក។ សូមទៅកាន់ហិបឆ្នោត រួចប្រាប់ឈ្មោះ និង អាសយដ្ឋានអ្នកទៅមន្ត្រីហិបឆ្នោត។ សូមដាក់សន្លឹកឆ្នោតអ្នកចូលក្នុងហិបឆ្នោត។ ហាមដាក់ទាំងស្រោមសម្ងាត់សន្លឹកឆ្នោតចូលជាមួយសន្លឹកឆ្នោតទៅក្នុងហិបឆ្នោត។